**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៤៩ សហវ.ប្រក.

លិខិតចូល
ថ្ងៃទី ៣១ ខែ ... ឆ្នាំ 2008

# ប្រកាស
# ស្តីពី
# គោលការណ៍ណែនាំផ្នែកគណនេយ្យ សម្រាប់អាជីវកម្មធានារ៉ាប់រងទូទៅ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និងការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៨៤ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ :**

ដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំផ្នែកគណនេយ្យ សំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តនៅកម្ពុជា។

**ប្រការ ២ : របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

១) គ្រប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងបន្តនៅកម្ពុជា ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៃឆ្នាំហិរញ្ញវត្ថុនីមួយៗ (ពីថ្ងៃទី ១ ខែ មករា ដល់ ថ្ងៃទី ៣១ ខែ ធ្នូ) តាមគំរូដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ នៃ ប្រកាសនេះ។

២) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មានមូលដ្ឋានលើបទដ្ឋានគណនេយ្យកម្ពុជា បទដ្ឋានសនវកម្មកម្ពុជា និងបទដ្ឋានរបាយការណ៍ហិរញ្ញវត្ថុកម្ពុជា ស្តីពីការធានារ៉ាប់រង។ ក្នុងករណីដែលបទដ្ឋានខាងលើ មិនបានបញ្ជាក់អំពីប្រព្រឹត្តកម្មគណនេយ្យ ឬតម្រូវការបើកចំហព័ត៌មាន បទដ្ឋានរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិត្រូវបានប្រើជំនួស។

៣) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវភ្ជាប់ជូនមកជាមួយនូវ លិខិតរបស់នាយកក្រុមហ៊ុន ដែលបញ្ជាក់អះអាងលើស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុនធានារ៉ាប់រងនោះ។

៤) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវភ្ជាប់ជូនមកជាមួយនូវរបាយការណ៍ របកគំហើញរបស់សវនករឯករាជ្យ ដែលឆ្លុះបញ្ចាំងអំពីចំនុចខ្សោយ ដែលបណ្តាលឱ្យមានផលប៉ះពាល់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន ការផ្តល់អនុសាសន៍ និងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង ក្នុងគោលបំណងពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និងធានាថានីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងនោះមានភាពគ្រប់គ្រាន់ ដើម្បីឱ្យរបាយការណ៍ហិរញ្ញវត្ថុមានតម្លាភាព។

៥) របាយការណ៍ប្រចាំឆ្នាំសម្រាប់ភាគទុនិក នឹងត្រូវបោះផ្សាយជារៀងរាល់ឆ្នាំនៅក្នុងអំឡុងពេលនៃឆមាសទី១។

**ប្រការ ៣ : សវនការគណនេយ្យឯករាជ្យ**

១) នៅក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីការបិទការិយបរិច្ឆេទនៃឆ្នាំហិរញ្ញវត្ថុនីមួយៗ ក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណទាំងអស់ ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុឆ្នាំមុន ដែលបានធ្វើសវនកម្មរួចដោយស្នងការគណនេយ្យឯករាជ្យ (សវនករ) ដែល:

ក) ជាសមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា។

ខ) មាននៅក្នុងតារាងវិជ្ជាជីវៈសវនករ ដែលទទួលការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២) ក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណ ត្រូវស្នើឈ្មោះស្នងការគណនេយ្យឯករាជ្យ ដែលមានបំណងផ្តល់សេវាកម្មដល់ក្រុមហ៊ុនរបស់ខ្លួននៃឆ្នាំនីមួយៗ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំប្រតិទិននីមួយៗនោះ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិបដិសេធស្នងការគណនេយ្យឯករាជ្យ ដែលក្រុមហ៊ុនធានារ៉ាប់រងបានស្នើ។

៣) សវនកររបស់ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបញ្ជាក់មតិយោបល់របស់ខ្លួនថាតើ:

ក) បានទទួលរាល់ព័ត៌មាន និងការបំភ្លឺដែលចាំបាច់ ដើម្បីធ្វើសវនកម្មដែរឬទេ។

ខ) យោងតាមព័ត៌មានដែលសវនករបានទទួល របាយការណ៍លទ្ធផល និងតារាងតុល្យការមានភាពពិត និងត្រឹមត្រូវឬទេ។

គ) ក្រុមហ៊ុនធានារ៉ាប់រង បានរក្សាទុកបញ្ជីគណនេយ្យរបស់ខ្លួនបានត្រឹមត្រូវឬទេ។

ឃ) សវនករបានទទួលរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ និងគ្រប់គ្រាន់ដើម្បីធ្វើសវនកម្មពីការិយាល័យរបស់ក្រុមហ៊ុនធានារ៉ាប់រងដែរឬទេ។

៤) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចតម្រូវឱ្យសវនករ:

ក) ផ្តល់ព័ត៌មានបន្ថែម និងស្រាយបំភ្លឺលើបញ្ហា ដែលទាក់ទងនឹងសវនកម្ម តាមការចង្អុលបង្ហាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ខ) ធ្វើសវនកម្មបន្ថែម តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចកំណត់ពេលវេលា

ដែលត្រូវធ្វើសវនកម្ម និងណែនាំក្រុមហ៊ុនធានារ៉ាប់រងឱ្យបង់សោហ៊ុយសវនកម្មទៅឱ្យសវនករ។

៥) ស្នងការគណនេយ្យឯករាជ្យ ត្រូវផ្តល់របាយការណ៍ដោយឡែកមួយជាបន្ទាន់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រសិនបើក្នុងអំឡុងពេលធ្វើសវនកម្មគាត់បានរកឃើញថា :

ក) មានការបំពានលើបទប្បញ្ញត្តិនៃច្បាប់ធានារ៉ាប់រង និងបទប្បញ្ញត្តិផ្សេងទៀត ឬក្រុមហ៊ុនធានារ៉ាប់រង ឬបុគ្គលិករបស់ក្រុមហ៊ុនធានារ៉ាប់រងបានប្រព្រឹត្តការក្លែងបន្លំ និងការមិនស្មោះត្រង់ ដែលផ្ទុយនឹងច្បាប់ដែលមានជាធរមាន។

ខ) ភាពមិនប្រក្រតី ដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកប្រើប្រាស់ ឬម្ចាស់បំណុលរបស់ក្រុមហ៊ុនធានារ៉ាប់រង ឬភាពមិនប្រក្រតីធ្ងន់ធ្ងរផ្សេងទៀត ដែលបានកើតឡើង។

គ) មិនបានបំពេញលក្ខខណ្ឌនៃកម្រិតសាធនភាព។

៦) ស្នងការគណនេយ្យឯករាជ្យរបស់ក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណមិនត្រូវទទួលខុសត្រូវលើការប្រព្រឹត្តផ្ទុយនឹងកាតព្វកិច្ច រក្សាការសម្ងាត់វិជ្ជាជីវៈ រវាងសវនករ និងក្រុមហ៊ុនធានារ៉ាប់រង ក្នុងការរាយការណ៍មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងបំណងបំពេញតាមប្រការ ៣(៤) និង ៣(៥)។

## ប្រការ ៤ : ស្ថិតិធានារ៉ាប់រង

គ្រប់ក្រុមហ៊ុនធានារ៉ាប់រង ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវស្ថិតិដែលទាក់ទងនឹងអាជីវកម្មធានារ៉ាប់រង តាមកាលកំណត់ និងគំរូបែបបទរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ប្រការ ៥ : ចំណូលបុព្វលាភ

គោលការណ៍អនុវត្តសម្រាប់ចំណូលបុព្វលាភ រួមមាន :

ក) បុព្វលាភត្រូវចាត់ទុកជាចំណូល នៅថ្ងៃចេញកិច្ចសន្យារ៉ាប់រង។ បុព្វលាភនៃ

ប័ណ្ណសន្យារ៉ាប់រងដែលមានអាយុកាលច្រើនជាង ១២ (ដប់ពីរ) ខែ ត្រូវផ្តល់ព័ត៌មានដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បុព្វលាភដែលត្រូវចាត់ទុកជាចំណូលពីប័ណ្ណសន្យារ៉ាប់រងទាំងនោះ ត្រូវសមាមាត្រជាមួយនឹងកម្រិតហានិភ័យ។

ខ) តំលៃនៃបុព្វលាភមិនទាន់ទទួលទាំងអស់ រួមទាំងសមតុល្យរបស់ភ្នាក់ងារធានារ៉ាប់រង និងសមតុល្យធានារ៉ាប់រងបន្ត មិនត្រូវមានចំនួនលើសតម្លៃបុព្វលាភមិនទាន់ទទួល ដកចេញនូវសំវិធានធនសម្រាប់បំណុលអាក្រក់ និងបំណុលសង្ស័យបានឡើយ។ ក្នុងន័យនេះ បុព្វលាភណាក៏ដោយ រួមទាំងសមតុល្យរបស់ភ្នាក់ងារធានារ៉ាប់រង និងសមតុល្យធានារ៉ាប់រងបន្ត ដែលនៅតែមិនទាន់បានទទួលលើសពីរយៈពេល ៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃដែលត្រូវទទួល នឹងត្រូវចាត់ទុកជា "បំណុលអាក្រក់ និងបំណុលសង្ស័យ"។ ដូច្នេះ សំវិធានធនសម្រាប់រាល់បំណុលទាំងនោះដែលមានរយៈពេលលើសពី ៦ (ប្រាំមួយ)ខែ ត្រូវកត់ត្រាជាសំវិធានធនទាំងស្រុង។ ចំពោះបំណុលអាក្រក់ណាដែលមានរយៈពេលតិចជាង ៦ (ប្រាំមួយ)ខែ ប៉ុន្តែមានការសង្ស័យ ត្រូវកំណត់ជាសំវិធានធនសម្រាប់បំណុលអាក្រក់។

**ប្រការ ៦ : ទុនបម្រុងសម្រាប់បុព្វលាភមិនទាន់រកបាន**

១) ទុនបម្រុងសម្រាប់ហានិភ័យមិនទាន់ផុតកំណត់ចំពោះអាជីវកម្មធានារ៉ាប់រងទូទៅ នឹងត្រូវគណនាដោយប្រើវិធីសាស្ត្រ ១/៨,១/២៤,១/៣៦៥ ឬ៤០ភាគរយ។ ទុនបម្រុងសម្រាប់ហានិភ័យមិនទាន់ផុតកំណត់ នឹងកំណត់ដោយផ្អែកលើមូលដ្ឋាននៃបុព្វលាភដុល ដកចេញការធានារ៉ាប់រងបន្តដែលបានធានានៅក្នុងអំឡុងពេលនោះ។ ក្នុងន័យនេះ នឹងត្រូវធ្វើឡើងដោយយកបុព្វលាភដុល ដកនូវរាល់ការធានារ៉ាប់រងបន្ត រួមទាំងការធានារ៉ាប់រងបន្តលើហានិភ័យពិសេស និងការធានារ៉ាប់រងបន្ត ចំពោះប្រាក់តំកល់ជាទុនបម្រុងអប្បបរមាបានរក្សាទុក។

២) បំណុលនៃហានិភ័យមិនទាន់ផុតកំណត់ ត្រូវកំណត់តម្លៃតាមមូលដ្ឋានសម្មតិកម្មជាក់លាក់មួយនៃបុព្វលាភទទួលបាន និងបំណុលមិនទាន់ផុតកំណត់ ដែលទាក់ទងនឹងបុព្វលាភទាំងនេះ។ ការកំណត់តម្លៃនេះមិនត្រូវតិចជាងចំនួនដែលកំណត់ដោយវិធីសាស្ត្រ ១/៨ សម្រាប់ប្រភេទអាជីវកម្មធានារ៉ាប់រងមិនមែននាវា តួនាវា និងអាកាសចរណ៍ ឬ តិចជាង២៥% ចំពោះអាជីវកម្មដឹកទំនិញតាមនាវា។

៣) ក្រុមហ៊ុនត្រូវកំណត់វិធីសាស្ត្រណាមួយដើម្បីអនុវត្ត ហើយត្រូវជូនដំណឹងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការអនុម័ត។ ក្នុងករណីចង់ប្តូរវិធីសាស្ត្រ ត្រូវជូនដំណឹងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលការឯកភាពជាមុន។

## ប្រការ ៧ : សំណងដែលនឹងត្រូវទូទាត់

គោលការណ៍អនុវត្តលើគណនេយ្យសម្រាប់ប្រាក់សំណង រួមមាន :

១) សំវិធានធនសម្រាប់សំណងមិនទាន់ទូទាត់ សម្រាប់អាជីវកម្មធានារ៉ាប់រងទូទៅ នឹងត្រូវគណនាដោយប្រើវិធីសាស្ត្រសំណងមិនទាន់ទូទាត់ ដែលអាចទទួលយកបាន។ ចំពោះសំវិធានធនសម្រាប់សំណងដែលនឹងត្រូវទូទាត់ដែលត្រូវប្រើជាមូលដ្ឋាន គឺផ្អែកលើវិធីសាស្ត្រករណីនីមួយៗ។ ចំណែកទុនបម្រុង អាចប្រើវិធីសាស្ត្រផ្សេងទៀត ដូចជា វិធីសាស្ត្រតម្លៃមធ្យម ឬវិធីសាស្ត្របមន្ត ដើម្បីវាយតម្លៃសំវិធានធនឱ្យបានគ្រប់គ្រាន់។ វិធីសាស្ត្រគណិតវិទ្យា ក្នុងការកំណត់ទុនបម្រុងសម្រាប់សំណង មិនអាចយកមកប្រើជំនួសវិធីសាស្ត្រតាមករណីបានឡើយ។

វិធីសាស្ត្រតម្លៃមធ្យម ឬវិធីសាស្ត្របមន្ត អាចប្រើបានតែក្នុងករណីដូចខាងក្រោម :

ក) សម្រាប់សំណងដែលមិនមានទិន្នន័យគ្រប់គ្រាន់ សម្រាប់ធ្វើការប៉ាន់ស្មានបំណុល។

ខ) សម្រាប់សំវិធានធន នៃសំណងដែលបានកើតឡើងប៉ុន្តែមិនទាន់រាយការណ៍។

គ) ដើម្បីពិនិត្យភាពគ្រប់គ្រាន់ នៃសំវិធានធនសម្រាប់សំណងមិនទាន់ទូទាត់។

២) របាយការណ៍អំពីសំណង នាដំណាច់ឆ្នាំហិរញ្ញវត្ថុ ត្រូវអនុវត្តដូចតទៅ :

ក) សំណង ត្រូវកត់ត្រានៅក្នុងបញ្ជីសំណងជាបន្ទាន់ នៅពេលទទួលដំណឹងជាលើកដំបូង ដោយមានការប៉ាន់ស្មានពីការចំណាយលើការខូចខាតផងដែរ។

ខ) សំវិធានធនសម្រាប់សំណង ត្រូវធ្វើឡើងដោយផ្អែកលើព័ត៌មានដែលមានទាំងអស់ ហើយសំវិធានធននោះ នឹងត្រូវត្រួតពិនិត្យឡើងវិញ និងកែតម្រូវទៅតាមព័ត៌មានថ្មីដែលមាន។ ចំពោះចំនួនទឹកប្រាក់សំណង ត្រូវកំណត់យកតាមការប៉ាន់ប្រមាណពីចំនួនទឹកប្រាក់ប្រហាក់ប្រហែលដែលត្រូវទូទាត់ ឱ្យបានត្រឹមត្រូវបំផុត ដោយផ្អែកលើរាល់ព័ត៌មានដែលមាន និងការសន្មត់នៃបំណុលដែលទទួលយកបាន។

គ) សំវិធានធនសម្រាប់សំណង មិនត្រូវកាត់បន្ថយដោយសារតែកង្វះឯកសារ ឬអ្នកទាមទារប្រាក់សំណងមិនបានឆ្លើយតបភ្លាមៗ ។ សំវិធានធន នឹងត្រូវរក្សាទុករហូតទាល់តែសំណងត្រូវបានលុបចោលទាំងស្រុង ឬផុតកំណត់។

ឃ) សំវិធានធនសម្រាប់សំណង មិនអាចលុបចោលទាំងស្រុង ដោយសារតែក្រុមហ៊ុនធានារ៉ាប់រង បានបដិសេធសំណងនោះបានឡើយ។ ករណីដែលការទាមទារសំណងណាមួយ មានទំហំលើសពីទំហំនៃការធានារ៉ាប់រង សំវិធានធននោះអាចនឹងត្រូវកាត់បន្ថយឱ្យនៅត្រឹមកម្រិតមួយ ដែលអាចទូទាត់សោហ៊ុយផ្លូវច្បាប់ ហើយនឹងបង្ការក្នុងករណីដែលមានបណ្តឹងទៅតុលាការ។ សំវិធានធននេះអាចលុបចោលទាំងស្រុងបន្ទាប់ពីរយៈពេល ១២ (ដប់ពីរ)ខែ ប្រសិនបើគ្មានការវិវត្តន៍ណាមួយទេ។

ង) នៅពេលដែលសំណងត្រូវបានបដិសេធ ដោយសារការបំពានលើកិច្ចសន្យា ឬលក្ខខណ្ឌធានារ៉ាប់រងណាមួយ ក្រុមហ៊ុនធានារ៉ាប់រងមិនអាចលុបសំវិធានធនសម្រាប់សំណងនោះ ចេញពីបញ្ជីរបស់ខ្លួន

បានឡើយ រហូតដល់ផុតកាលកំណត់នៃការធ្វើសំណង។ ទោះបីជាយ៉ាងណាក៏ដោយ សិវិធានធននោះ អាចកាត់បន្ថយឱ្យនៅត្រឹមចំនួនដែលគិតថាគ្រប់គ្រាន់ ទៅតាមស្ថានភាពនៃការបំពានកិច្ចសន្យា ដោយមានការឯកភាពពីគណៈគ្រប់គ្រងជាន់ខ្ពស់។

ច) សិវិធានធនសម្រាប់រាល់សំណងមិនទាន់ទូទាត់ ត្រូវតែមានការត្រួតពិនិត្យឡើងវិញ យ៉ាងហោចណាស់ក្នុងមួយឆ្នាំម្តង ដោយបុគ្គលិកជំនាញដែលមានបទពិសោធន៍គ្រប់គ្រាន់។

ឆ) គណៈគ្រប់គ្រងក្រុមហ៊ុន ត្រូវពិនិត្យឡើងវិញជាទៀងរាល់ខែពីភាពគ្រប់គ្រាន់នៃសិវិធានធនលើសំណង ដោយផ្ទៀងផ្ទាត់នូវចំនួនដែលបានបង់ជាមួយនឹងសិវិធានធនដែលមានចំពោះសំណងទាំងនោះ។ ក្នុងពេលពិនិត្យឡើងវិញ បើឃើញថាទុនបម្រុងមានមិនគ្រប់គ្រាន់ទេ ត្រូវចាត់វិធានការកែតម្រូវជាបន្ទាន់។

ជ) នៅចុងឆ្នាំ គណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់នៃសិវិធានធន ដោយប្រើវិធីសាស្ត្រស្ថិតិ ដូចជា វិធីសាស្ត្រចំណាយមធ្យមលើសំណង ឬលំនាំនៃការប្រែប្រួលសំណង។

៣) សិវិធានធនដែលសមល្មមសម្រាប់សំណង ដែលបានកើតឡើងប៉ុន្តែមិនទាន់រាយការណ៍ ត្រូវកំណត់ដោយផ្អែកលើលំនាំសំណងជាក់ស្តែង ដែលបានកើតមានក្នុងពេលថ្មីៗកន្លងមក ហើយប៉ាន់ប្រមាណទៅអនាគត ដោយពិចារណាដល់កត្តាដូចខាងក្រោម:

ក) កំណើនអាជីវកម្ម ដែលរួមមាន បុព្វលាភ ទឹកប្រាក់ធានា ចំនួនហានិភ័យ និងអាជីវកម្មទាំងមូល។

ខ) ករណីដែលមានបណ្តឹងទាមទារសំណង រួមមាន ចំនួន និងបរិមាណទឹកប្រាក់សំណង ដែលទាក់ទងនឹងទំហំអាជីវកម្ម។

គ) សំណងដែលកើតឡើងសម្រាប់ឆ្នាំប្រតិបត្តិការមួយ ប្រៀបធៀបនឹងឆ្នាំកន្លងទៅ ដោយផ្អែកលើលំនាំនៃការរាយការណ៍ និងការដោះស្រាយសំណង។

ឃ) ផលប៉ះពាល់នៃអតិផរណា មកលើចំនួនទឹកប្រាក់សំណង និងការព្យាករណ៍សម្រាប់អនាគត។

ង) ប្រៀបធៀបនឹងនិន្នាការទីផ្សារ តាមលទ្ធភាពដែលអាចធ្វើទៅបាន។

៤) នៅពេលកំណត់ចំណែក ដែលត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រងបន្ត សម្រាប់សំណងមិនទាន់ទូទាត់ ត្រូវមានការប្រុងប្រយ័ត្នដោយមិនត្រូវរាប់បញ្ចូលនូវអ្វីដែលត្រូវទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ក្នុងករណីដែលៈ

ក) ក្រុមហ៊ុនធានារ៉ាប់រងបន្តនោះ មិនអាចសងបំណុលបាន (អសាធនភាព)។

ខ) ក្រុមហ៊ុនធានារ៉ាប់រងបន្តនោះ បានបដិសេធសំណងនោះ ដោយហេតុផលផ្សេងៗ។

គ) ការទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងបន្ត មានការលំបាកដោយហេតុផលផ្សេងៗ។

**ប្រការ ៨ : សន្និសញ្ញាទទួលហានិភ័យធានារ៉ាប់រង**

តាមធម្មតា បទដ្ឋានគណនេយ្យធានារ៉ាប់រង អនុញ្ញាតឱ្យក្រុមហ៊ុនធានារ៉ាប់រងទទួលហានិភ័យតាមសន្និសញ្ញា ហើយអាចប្រើប្រាស់វិធីសាស្ត្រគណនេយ្យធានារ៉ាប់រងចំហ។

ក្រុមហ៊ុនធានារ៉ាប់រង អាចប្រើប្រាស់វិធីសាស្ត្រនេះ បន្ទាប់ពីទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅពេលទទួលបានការឯកភាពហើយ ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំដូចខាងក្រោមៈ

១) នៅពេលក្រុមហ៊ុនធានារ៉ាប់រង សម្រេចចិត្តប្រើប្រាស់វិធីសាស្ត្រគណនេយ្យធានារ៉ាប់រងចំហ ក្រុមហ៊ុនត្រូវតែប្រើវិធីសាស្ត្រគណនេយ្យនេះនៅឆ្នាំជាបន្តបន្ទាប់។ ប្រសិនបើ ក្រុមហ៊ុនធានារ៉ាប់រង មានបំណងប្តូរទៅវិធីសាស្ត្រគណនេយ្យ តាមឆ្នាំការិយបរិច្ឆេទ ក្រុមហ៊ុនត្រូវតែផ្តល់ហេតុផលនៃការសម្រេចចិត្តផ្លាស់ប្តូរនោះ និងមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២) ឆ្នាំធានារ៉ាប់រង ត្រូវតែទុកបើកចំហសម្រាប់រយៈពេលអតិបរមា ៣៦ (សាមសិបប្រាំមួយ)ខែ ដែលនៅចុងរយៈកាលនៃឆ្នាំធានារ៉ាប់រងនោះ ត្រូវបិទបញ្ជីដោយមានសមតុល្យឥណពន្ធ និងប៉ាន់ប្រមាណពីបំណុលមិនទាន់ទូទាត់សម្រាប់ឆ្នាំនោះឱ្យបានត្រឹមត្រូវ ហើយធ្វើការផ្ទេរបំណុល និងមូលនិធិដែលមានតម្លៃស្មើ ទៅក្នុងឆ្នាំធានារ៉ាប់រងចំហបន្ទាប់ទៀត។

៣) រាល់ចំណូលដែលត្រូវទទួលពីក្រុមហ៊ុនផ្ទេរហានិភ័យ និងរាល់ចំណាយដែលត្រូវទូទាត់ឱ្យក្រុមហ៊ុនផ្ទេរហានិភ័យ ដែលទាក់ទងនឹងប្រតិបត្តិការធានារ៉ាប់រងបន្តត្រូវបញ្ចូលជាមូលនិធិ។ ចំណូលផ្សេងទៀត ដូចជាចំណូលពីវិនិយោគ ឬចំណាយផ្សេងទៀត មិនត្រូវកត់ត្រា ឬបញ្ចូលក្នុងមូលនិធិទេ។

៤) នៅចុងការិយបរិច្ឆេទគណនេយ្យនៃឆ្នាំធានារ៉ាប់រងចំហនីមួយៗ ត្រូវមានមូលនិធិគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចសំណងចំពោះហានិភ័យដែលមិនទាន់ផុតកំណត់ និងកាតព្វកិច្ចចំពោះការទាមទារសំណងមិនទាន់ទូទាត់ (រួមទាំងការទាមទារសំណងដែលបានកើតឡើងប៉ុន្តែមិនទាន់រាយការណ៍)។ ប្រសិនបើមូលនិធិនោះត្រូវបានរកឃើញថា មានមិនគ្រប់គ្រាន់ ក្រុមហ៊ុនត្រូវបំពេញភាពមិនគ្រប់គ្រាន់នោះឱ្យបានត្រឹមត្រូវជាបន្ទាន់ ដោយធ្វើការផ្ទេរប្រាក់ឱ្យបានគ្រប់ចំនួន ចូលទៅក្នុងមូលនិធិនោះ។

៥) ប្រសិនបើមូលនិធិធានារ៉ាប់រងក្លាយជាអវិជ្ជមាន ដោយសារមិនទាន់បានទទួលបុព្វលាភ មូលនិធិនោះត្រូវរក្សាឱ្យមានសមតុល្យវិជ្ជមាន ដោយមិនគិតពីទស្សនៈរបស់ក្រុមហ៊ុន អំពីលទ្ធផលចុងក្រោយដែលត្រូវទទួលបានសម្រាប់ឆ្នាំធានារ៉ាប់រងនោះឡើយ។ មូលនិធិនោះត្រូវបង្កើនបន្ថែមទៀតឱ្យដល់កម្រិតមួយដែលគ្រប់គ្រាន់ ដើម្បីទូទាត់រាល់បំណុលដែលត្រូវសង។

៦) បំណុលសម្រាប់ហានិភ័យមិនទាន់ផុតកំណត់ ត្រូវវាយតម្លៃដោយផ្អែកលើមូលដ្ឋាននៃសម្មតិកម្មជាក់លាក់ ឱ្យស្របទៅតាមបុព្វលាភដែលមាន និងបំណុលមិនទាន់ផុតកំណត់ ដែលទាក់ទងនឹងបុព្វលាភទាំងនោះ។ កាតព្វកិច្ចសងបំណុលនេះ មិនត្រូវតិចជាងចំនួនដែលបានកំណត់ដោយវិធីសាស្ត្រ ១/៨ សម្រាប់ប្រភេទអាជីវកម្មធានារ៉ាប់រងមិនមែននាវា ចូនាវា និងអាកាសចរណ៍ ឬវិធីសាស្ត្រ ២៥% ចំពោះអាជីវកម្មដឹកទំនិញតាមនាវា។

៧) ក្រុមហ៊ុនត្រូវធ្វើការប៉ាន់ប្រមាណប្រាក់សំណងមិនទាន់ទូទាត់ ចំពោះសន្ធិសញ្ញានីមួយៗ ដោយប្រើមធ្យោបាយល្អបំផុត ដែលអាចធ្វើបានផ្អែកលើទិន្នន័យដែលមាន។ ការប៉ាន់ប្រមាណនេះ ត្រូវបំពេញដោយការវាយតម្លៃសំណងដែលបានកើតឡើងប៉ុន្តែមិនទាន់រាយការណ៍ ឱ្យបានសមស្រប។ ក្នុងគោលបំណងនេះ ក្រុមហ៊ុនធានារ៉ាប់រង ត្រូវពិចារណារៀបចំទិន្នន័យដាច់ដោយឡែកពីគ្នា សម្រាប់ប្រភេទអាជីវកម្មនីមួយៗ ដូចជា អគ្គីភ័យ

តួនាទី ការដឹកទំនិញតាមនាវា វិស្វកម្ម សម្រាប់សន្ធិសញ្ញាសមាមាត្រ ការធានារ៉ាប់រងបន្ត និងសន្ធិសញ្ញាទទួលសងលើសពីការខាត។ ក្រៅពីនេះការសិក្សាពីការវិវត្តន៍ នៃសំណងទៅតាមបទពិសោធន៍ផ្ទាល់របស់ក្រុមហ៊ុន ស្របតាមការវិវត្តន៍នៃសំណងនៅក្នុងទីផ្សារ ដោយផ្អែកលើទិន្នន័យដែលមាន។

**ប្រការ ៩ : ទ្រព្យសកម្ម**

១) ទ្រព្យសកម្មដែលត្រូវកែតម្រូវ ត្រូវកំណត់ដូចខាងក្រោម :

ក) តម្លៃទ្រព្យសកម្មដែលជាបន្ទុក ឬជាប់សន្យា ឬខ្ចីមិនត្រូវរាប់បញ្ចូលឡើយ។

ខ) ទ្រព្យសកម្មអរូបី ត្រូវបានរាប់បញ្ចូល លើកលែងតែមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរាប់បញ្ចូលនូវទ្រព្យសកម្មអរូបីមួយផ្នែក ឬទាំងស្រុង។

គ) ការផ្តល់ប្រាក់កម្ចី ការធ្វើវិនិយោគ ការផ្តល់ប្រាក់បុរេប្រទាន ឬបំណុល ដែលត្រូវទទួលពីនាយក បុគ្គលិក សហការី ឬភាគីពាក់ព័ន្ធ ព្រមទាំងក្រុមហ៊ុនជំពាក់ត្រូវបានដកចេញ។

២) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិធ្វើការណែនាំជាលាយលក្ខណ៍អក្សរ ដល់ក្រុមហ៊ុនធានារ៉ាប់រង :

ក) មិនត្រូវវិនិយោគលើទ្រព្យសកម្មប្រភេទណាមួយ។

ខ) ត្រូវលក់ចេញនូវទ្រព្យសកម្មវិនិយោគមួយផ្នែក ឬទាំងស្រុងនៅមុនផុតរយៈកាលកំណត់ ឬរយៈកាលពន្យារ។

៣) ការវាយតម្លៃទ្រព្យសកម្ម ត្រូវផ្អែកលើមូលដ្ឋានតាមប្រភេទទ្រព្យសកម្មនីមួយៗ :

**ក) អចលនទ្រព្យ**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃទ្រព្យវិនិយោគនៅក្នុងគណនីទ្រព្យវិនិយោគតាមថ្លៃដើម ឬតម្លៃដែលបានវាយតម្លៃឡើងវិញ ដោយអ្នកវាយតម្លៃ និងត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមហ៊ុនធានារ៉ាប់រងដែលវាយតម្លៃទ្រព្យវិនិយោគឡើងវិញ នៅក្នុងគណនីទ្រព្យវិនិយោគ ត្រូវធ្វើការវាយតម្លៃឡើងវិញរៀងរាល់ ៣ (បី) ឆ្នាំម្តង ឬឆាប់ជាងនេះ ក្នុងករណីដែលតម្លៃទីផ្សារថយចុះលើសពី ១០ (ដប់) ភាគរយ។

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃទ្រព្យដែលក្រុមហ៊ុនកាន់កាប់ផ្ទាល់នៅក្នុងគណនីមួយតាមថ្លៃដើម ដករំលស់បង្គរ ឬវាយតម្លៃឡើងវិញ ដោយអ្នកវាយតម្លៃដែលមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវធ្វើការវាយតម្លៃទ្រព្យកាប់កាប់ផ្ទាល់ឡើងវិញ រៀងរាល់ ១០ (ដប់) ឆ្នាំម្តង ឬឆាប់ជាងនេះក្នុងករណីតម្លៃទីផ្សារថយចុះលើសពី ១០ (ដប់) ភាគរយ។

"ទ្រព្យកាន់កាប់ផ្ទាល់" ខាងលើមានន័យថា ជាអចលនទ្រព្យដែលមានក្រឡាផ្ទៃលើសពីហាសិប ៥០ (ហាសិប) ភាគរយ កាន់កាប់ដោយក្រុមហ៊ុនធានារ៉ាប់រងនោះ។

អ្នកវាយតម្លៃ មានន័យថា ក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ខ) មូលបត្រសាជីវកម្ម**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវកំណត់តម្លៃមូលបត្រ ដោយយកតាមថ្លៃដើម ឬតម្លៃទីផ្សារ (មូលបត្រមហាជន) ដែលទាបជាងគេ។ ប្រសិនបើ តម្លៃវិនិយោគក្នុងរយៈពេល ២៤ (ម្ភៃបួន)ខែ ទាបជាងថ្លៃដើម រហូតដល់ ២០ (ម្ភៃ) ភាគរយ វិនិយោគនោះត្រូវបានចាត់ទុកថាមានការធ្លាក់ថ្លៃជាអចិន្ត្រៃយ៍ ដែលតម្រូវឱ្យធ្វើសំវិធានធនសម្រាប់ការធ្លាក់ថ្លៃនៃវិនិយោគនោះ។

ក្រុមហ៊ុនធានារ៉ាប់រង ដែលកាន់កាប់ភាគហ៊ុនមិនមាននៅក្នុងទីផ្សារមូលបត្រ ហើយភាគហ៊ុននោះមានតម្លៃជាក់ស្តែងខ្ពស់ជាងថ្លៃដើម អាចត្រូវអាចត្រូវអនុញ្ញាតឱ្យវាយតម្លៃឡើងវិញ តាមតម្លៃជាក់ស្តែង ដោយមានការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**គ) ប្រាក់កម្ចី**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃប្រាក់កម្ចីដែលមិនទាន់បានទទួល តាមចំនួនទឹកប្រាក់ ដែលមិនលើសចំនួនប្រាក់ដើមដែលត្រូវទទួល ឬតាមតម្លៃជាក់ស្តែងនៃប្រាក់កម្ចី ដោយយកចំនួនទឹកប្រាក់ដែលទាបជាងគេ។

**ឃ) មូលបត្ររដ្ឋ**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃមូលបត្ររដ្ឋ ឬប័ណ្ណផ្សេងទៀត ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមតម្លៃមូលបត្រ ដែលប្រែប្រួលនៅឥណប្រតិទាន ដោយប្រើវិធីសាស្ត្ររំលស់ថេរ ឬវិធីសាស្ត្រទិន្នផលថេរ។

**ង) ប្រាក់បញ្ញើ**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃប្រាក់បញ្ញើនៅស្ថាប័នហិរញ្ញវត្ថុ ដែលទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងប្រាក់បញ្ញើនៅធនាគារដែលទទួលអាជ្ញាប័ណ្ណពីអាជ្ញាធរនៃប្រទេសផ្សេងៗ ដោយយកតាមតម្លៃចុះបញ្ជីនៃប្រាក់បញ្ញើនោះ។

**ច) ប្រាក់ត្រូវទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ឬក្រុមហ៊ុនផ្ទេរហានិភ័យ**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃទឹកប្រាក់ដែលត្រូវទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ឬក្រុមហ៊ុនផ្ទេរហានិភ័យ រួមទាំង ប្រាក់បញ្ញើរក្សាទុកតាមចំនួនទឹកប្រាក់ត្រូវទទួល បន្ទាប់ពីបានដកចេញនូវសំវិធានធនសម្រាប់បំណុលអាក្រក់ និងបំណុលសង្ស័យ។

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃប្រាក់សំណងត្រូវទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត តាមចំនួនទឹកប្រាក់មិនលើសពីចំនួនទឹកប្រាក់មិនទាន់ទទួល បន្ទាប់ពីការដកចេញនូវបំណុលអាក្រក់ និងបំណុលសង្ស័យ។

ក្នុងករណីដែល ក្រុមហ៊ុនធានារ៉ាប់រង មានទឹកប្រាក់ត្រូវទទួលក្នុងរយៈពេលលើសពី ៦ (ប្រាំមួយ)ខែ ដោយគិតចាប់តាំងពីថ្ងៃដែលត្រូវទទួលត្រូវចាត់ទុកជាបំណុលសង្ស័យ។

**ឆ) បុព្វលាភត្រូវទទួល**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃចំនួនសរុបនៃបុព្វលាភត្រូវទទួលពីអ្នកប្រើប្រាស់ ភ្នាក់ងារ ជើងសា និង អន្តរការីផ្សេងទៀត តាមចំនួនទឹកប្រាក់ដែលត្រូវទទួល បន្ទាប់ពីដកសំវិធានធនសម្រាប់បំណុលអាក្រក់ និងបំណុលសង្ស័យ។ ថ្វីបើមានចែងខាងលើ ក្រុមហ៊ុនធានារ៉ាប់រង ត្រូវចាត់ទុករាល់ចំនួនទឹកប្រាក់ត្រូវទទួលក្នុងរយៈពេលលើសពី ៦ (ប្រាំមួយ)ខែ ចាប់ពីថ្ងៃចាប់ផ្តើមនៃបណ្ណសន្យាធានារ៉ាប់រង ជាបំណុលសង្ស័យ។

**ជ) ចំណូលវិនិយោគ**

ក្រុមហ៊ុនធានារ៉ាប់រង មិនត្រូវចាត់ទុកទឹកប្រាក់ត្រូវទទួលក្នុងរយៈពេលលើសពី ៦ (ប្រាំមួយ)ខែ ជាចំណូលវិនិយោគដែលក្រុមហ៊ុនត្រូវទទួលឡើយ។

**ឈ) គ្រឿងសង្ហារឹម និងឧបករណ៍ផ្សេងៗ**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃគ្រឿងសង្ហារឹម ឧបករណ៍ការិយាល័យ យានយន្ត និងឧបករណ៍កុំព្យូទ័រ តាមថ្លៃដើមដកចេញរំលស់បង្គរ។

**ញ) ទ្រព្យសកម្មផ្សេងទៀត**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុន តាមបទដ្ឋានគណនេយ្យកម្ពុជា ដែលអនុម័តដោយក្រុមប្រឹក្សាជាតិគណនេយ្យ ក្នុងករណីដែលមិនមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីការធានារ៉ាប់រង។

**ប្រការ ១០ : ការត្រួតពិនិត្យគណនេយ្យ**

១) យោងតាមមាត្រា ៩២ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង អ្នកត្រួតពិនិត្យដែលទទួលការអនុញ្ញាត ជាលាយលក្ខណ៍អក្សរពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រួតពិនិត្យដោយមិនចាំបាច់ជូនដំណឹងជាមុននូវឯកសាររបស់ :

ក) ក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណ ឬភ្នាក់ងារធានារ៉ាប់រងរបស់ក្រុមហ៊ុននោះ ទោះនៅក្នុង ឬនៅក្រៅប្រទេសកម្ពុជា ។

ខ) ក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណ ហើយកំពុងធ្វើការជម្រះបញ្ជី ឬក្រុមហ៊ុនធានារ៉ាប់រងដែលមិនទាន់បានទទួលអាជ្ញាប័ណ្ណថ្មី។

២) ក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណ :

ក) ត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីត្រួតពិនិត្យ ក្នុងការពិនិត្យរាល់ឯកសារពាក់ព័ន្ធរបស់ក្រុមហ៊ុន។

ខ) ត្រូវសម្រួលដល់ការអនុវត្តការត្រួតពិនិត្យនោះ។

គ) ត្រូវផ្តល់ព័ត៌មាន ដែលទាក់ទងនឹងអាជីវកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រង ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដល់មន្ត្រីត្រួតពិនិត្យ។

៣) មន្ត្រីត្រួតពិនិត្យអាចរឹបអូសឯកសារ ឬសាច់ប្រាក់ ដែលមន្ត្រីនោះពិនិត្យឃើញថា :

ក) ចាំបាច់សម្រាប់គោលបំណងនៃការចុះត្រួតពិនិត្យ រួមទាំងការថតចម្លង និងការដកហូតយកឯកសារផ្សេងៗ ។

ខ) ឯកសារអាចត្រូវបំផ្លាញចោល ដកចេញដោយក្រុមហ៊ុន ប្រសិនបើមន្ត្រីត្រួតពិនិត្យមិនបានរឹបអូសទុកឯកសារនោះ។

គ) ឯកសារនោះ នឹងក្លាយជាភស្តុតាងនៅក្នុងនីតិវិធីតុលាការ ដែលអាចប្តឹងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤) មន្ត្រីត្រួតពិនិត្យអាចត្រួតពិនិត្យ :

ក) បុគ្គលដែលជានាយក បុគ្គលិករបស់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង ឬក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង។

ខ) បុគ្គលដែលជាអ្នកប្រើប្រាស់ ដែលមានការពាក់ព័ន្ធនឹងក្រុមហ៊ុនធានារ៉ាប់រងនោះ។

គ) បុគ្គលដែលដឹងអំពីហេតុការណ៍ និងស្ថានភាពនៃករណីនោះ រួមទាំងសវនកររបស់ក្រុមហ៊ុនធានារ៉ាប់រងនោះផងដែរ។

ឃ) សវនករ នឹងមិនទទួលខុសត្រូវចំពោះការរំលោភកិច្ចសន្យាដែលទាក់ទងនឹងការរក្សាការសម្ងាត់វិជ្ជាជីវៈក្នុងការផ្តល់ឯកសារ ឬព័ត៌មានដល់មន្ត្រីត្រួតពិនិត្យ។

**ប្រការ ១១ :**

រដ្ឋមន្ត្រី និងមន្ត្រីនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលបំពេញការងារតាមការណែនាំរបស់រដ្ឋមន្ត្រី ឬនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នឹងមិនអាចត្រូវប្តឹងចំពោះការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដែលមានចែងនៅក្នុងប្រការ ១០ នៃប្រកាសនេះ ប្រសិនបើការបំពេញការងារនោះត្រូវបានធ្វើឡើងសុចរិតភាព។

**ប្រការ ១២ :**

បុគ្គលណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនពី ១០ (ដប់) លានរៀល ទៅ ២០ (ម្ភៃ) លានរៀល ដោយបង់ចូលរតនាគារជាតិតាមដីកាអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ១៣ :**

ប្រកាសលេខ ១៩៨ ស្តីពីគោលការណ៍ណែនាំផ្នែកគណនេយ្យចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៥ ត្រូវទុកជានិរាករណ៍។ រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៤ :**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ